**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការបរទេស**
**និងសហប្រតិបត្តិការអន្តរជាតិ**

លេខ ២៦១៤ កបទ.សអ/ច្បក២

ប្រញាប់ណាស់

**ជម្រាបមក**
**ឯកឧត្តម លោកជំទាវ ឯកអគ្គរាជទូត លោក លោកស្រី អគ្គកុងស៊ុល និង**
**កុងស៊ុលកិត្តិយស នៃព្រះរាជាណាចក្រកម្ពុជាប្រចាំនៅបរទេស**

កម្មវត្ថុ៖ ការហាមឃាត់ការធ្វើដំណើររបស់ជនបរទេសមកពីប្រទេសឥណ្ឌាចូលមកប្រទេសកម្ពុជា។
យោង៖ សេចក្តីប្រកាសព័ត៌មានចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២១ របស់ក្រសួងសុខាភិបាល។

ខ្ញុំសូមជម្រាបជូន **ឯកឧត្តម លោកជំទាវ** ឯកអគ្គរាជទូត លោក លោកស្រី អគ្គកុងស៊ុល និង កុងស៊ុលកិត្តិយស ថា ក្រសួងសុខាភិបាលបានសម្រេចហាមឃាត់ការធ្វើដំណើរចូលមកប្រទេសកម្ពុជា មួយរយៈ រហូតដល់មានការជូនដំណឹងជាថ្មី ចំពោះពលរដ្ឋឥណ្ឌា និងពលរដ្ឋបរទេសទាំងអស់ ដែលធ្វើដំណើរមកពីប្រទេសឥណ្ឌា ឬឆ្លងកាត់ប្រទេសឥណ្ឌា ឬមានប្រវត្តិធ្វើដំណើរទៅប្រទេសឥណ្ឌា រយៈពេល ៣សប្តាហ៍មុនចូលមកប្រទេសកម្ពុជា តាមផ្លូវអាកាស ឬតាមផ្លូវគោក ដោយអនុវត្តចាប់ពីថ្ងៃទី២៩ ខែមេសា ឆ្នាំ២០២១ នេះតទៅ ដូចមានជូនភ្ជាប់។

សូម **ឯកឧត្តម លោកជំទាវ** ឯកអគ្គរាជទូត លោក លោកស្រី អគ្គកុងស៊ុល និង កុងស៊ុលកិត្តិយស មេត្តាជ្រាប និងអនុវត្តតាមការសំរេចនេះឱ្យមានប្រសិទ្ធភាពខ្ពស់។

ថ្ងៃពុធ ០២រោច ខែពិសាខ ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី២៨ ខែមេសា ឆ្នាំ២០២១

**រដ្ឋមន្ត្រី**
**រដ្ឋលេខាធិការ**

**ស៊ា កុសល**

អាសយដ្ឋាន៖ លេខ ៣ វិថី សម្តេច ហ៊ុន សែន
សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ : (855) 23 216 122
ទូរសារ : (855) 23 216 141, 023 213 341
អ៊ីម៉ែល : mfaic@mfaic.gov.kh